AEON NEWS RELEASE

Planting Seeds of Growth
We are ÆON

ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២១
ក្រុមហ៊ុនអ៊ីអនម៉ល (ខេមបូឌា) ខូអិលធីឌី

– រួមចំណែកទប់ស្កាត់ការរីករាលដាលនៃ ជំងឺកូវីដ១៩ ដើម្បីធានា "សុវត្ថិភាព និង សន្តិសុខ" –

# ការបរិច្ចាគជំនួយថវិកា គាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការ ជំងឺកូវីដ១៩ ដល់រាជរដ្ឋាភិបាលកម្ពុជា

ដើម្បីជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងគោលបំណងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ និងធានា "សុវត្ថិភាពនិងសន្តិសុខ" ជូនប្រជាជនគ្រប់រូប នៅក្នុងសហគមន៍ នៃប្រទេសកម្ពុជា ក្រុមហ៊ុនចំនួន៤ នៃអ៊ីអនគ្រុបជប៉ុនដែលកំពុងប្រតិបត្តិការនៅប្រទេសកម្ពុជា រួមមាន ក្រុមហ៊ុនអ៊ីអន (ខេមបូឌា) ខូអិលធីឌី ក្រុមហ៊ុនអ៊ីអនម៉ល (ខេមបូឌា) ខូអិលធីឌី ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី និង ក្រុមហ៊ុនអ៊ីអន ឌីឡៃថ៍ (វៀតណាម) ខមភេនី លីមីធីត បានផ្តល់ជំនួយជាថវិកា សរុបចំនួន 50 លានយ៉េន (ប្រមាណ 454.545 ដុល្លាសហរដ្ឋអាមេរិក) ដល់ រាជរដ្ឋាភិបាលកម្ពុជា ដើម្បីគាំទ្រដល់យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩។ ក្នុងនោះ 15 លានយ៉េន (ប្រមាណ 136.363 ដុល្លាសហរដ្ឋអាមេរិក) ជាជំនួយថវិកាពីក្រុមហ៊ុនអ៊ីអនម៉ល (ខេមបូឌា) ខូអិលធីឌី។

ក្រុមហ៊ុនអ៊ីអនគ្រុបជប៉ុន បានប្រកាសបរិច្ចាគថវិកាសរុបចំនួន ៣៥០ លានយ៉េនដល់រដ្ឋាភិបាលនៃប្រទេសមួយចំនួនជាសមាជិកអាស៊ានរួមមានប្រទេសម៉ាឡេស៊ី ប្រទេសវៀតណាម ប្រទេសឥណ្ឌូនេស៊ី ប្រទេសថៃ និងប្រទេសកម្ពុជា ដើម្បីជំរុញយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងគោលបំណង ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ នេះផងដែរ។

ថ្វីត្បិតតែប្រទេសកម្ពុជាចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋរបស់ខ្លួន បានច្រើនបើប្រៀបធៀបទៅនឹងប្រទេសដែលជាសមាជិកអាស៊ានដទៃទៀតក៏ដោយ ក៏ប៉ុន្តែការរីករាលដាលនៅតែកំពុងបន្តនៅឡើយ។ គោលបំណងនៃការបរិច្ចាគនេះ គឺដើម្បីប្រើប្រាស់ ក្នុងការជំរុញ ពន្លឿន យុទ្ធនាការចាក់វ៉ាក់សាំង របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងការឆ្លងរីករាលដាល និងស្តារសេដ្ឋកិច្ចរបស់ប្រទេសឡើងវិញ។

ការបរិច្ចាគដល់រាជរដ្ឋាភិបាលកម្ពុជានេះ រួមមានការចូលរួមវិភាគទានពីក្រុមហ៊ុន អ៊ីអនគ្រុបជប៉ុន ដែលមានដូចជា AEON Co., Ltd., AEON MALL Co., Ltd., AEON Financial Services Co., Ltd., AEON Delight Co., Ltd., និងមកពី AEON 1% Club Foundation ។

ឈរលើគោលការណ៍មូលដ្ឋាន "ស្វែងរកសន្តិភាព គោរពមនុស្សជាតិ និងចូលរួមចំណែកដល់សហគមន៍មូលដ្ឋានដោយតែងតែ ស្ថិតនៅជាមួយទស្សនៈស្ទួល អតិថិជនជាចម្បង" ក្រុមហ៊ុន អ៊ីអនគ្រុប នឹងបន្តខិតខំប្រឹងប្រែងរួមគ្នា ដើម្បីបញ្ចប់ការរីករាលដាលនៃជំងឺកូវីដ១៩ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីស្តារ សន្តិសុខនិងសន្តិភាព ឡើងវិញនៅក្នុងការរស់នៅប្រចាំថ្ងៃរបស់សហគមន៍មូលដ្ឋាន។

**ព័ត៌មានបន្ថែម**

**ចំនួនហាង និងគ្រឹះស្ថានអាជីវកម្ម ក្នុងប្រទេសនីមួយៗ ដែលទទួលជំនួយថវិកា**

( គិតត្រឹម ចុងខែកុម្ភៈ ឆ្នាំ២០២១)

| ប្រទេស | GMS | SM DS | ហាងលក់រាយផ្សេងទៀត | ហិរញ្ញវត្ថុ | សេវាកម្ម | ផ្សារទំនើប(ម៉ល) |
|---|---|---|---|---|---|---|
| ម៉ាឡេស៊ី | ៣៣ | ៣២ | ៦៩ | ៦៥ | ៩៨ | ២៨ |
| វៀតណាម | ៦ | ២៣ | ១៥៨ | ៤ | ១៤ | ៦ |
| ឥណ្ឌូនេស៊ី | ៣ | - | - | ៩ | ២៨ | ៣ |
| ថៃ | - | ៤៧ | ១ | ១៣៤ | ២៧ | - |
| កម្ពុជា | ២ | ១២ | - | ១២ | ៣ | ២ |

ក្រុមហ៊ុន AEON Delight Co., Ltd. មានការិយាល័យសរុបចំនួន ១៤ ក្នុងនោះរួមមាន ១ នៅប្រទេសម៉ាឡេស៊ី ២ នៅប្រទេសវៀតណាម ១០ នៅប្រទេសឥណ្ឌូនេស៊ី និង ១ នៅប្រទេសកម្ពុជា។

SM : ផ្សារទំនើប (Supermarket)
DS : ផ្សារលក់បញ្ចុះតម្លៃ (Discount Store)
GMS : ហាងលក់ទំនិញរាយទូទៅ (General Merchandise Store)

**ព័ត៌មានសង្ខេបនៃពិធីបរិច្ចាគ**

- **កាលបរិច្ឆេទ**: ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២១(នាទីស្តីការក្រសួងសុខាភិបាល)
- **ថវិកាបរិច្ចាគ**: 50 លានយ៉េន (រាប់បញ្ចូលទាំងថ្លៃសេវាផ្ទេរថវិកា)
- **ទិសដៅនៃថវិកាបរិច្ចាគ**: រាជរដ្ឋាភិបាលកម្ពុជា
- **សមាសភាពចូលរួម**:

សមាសភាពពីក្រសួងសុខាភិបាល:

| **ឈ្មោះស្ថាប័ន** | **នាម·គោត្តនាម** | **មុខតំណែង** |
|---|---|---|
| ក្រសួងសុខាភិបាល | ឯកឧត្តម សាស្ត្រាចារ្យ ម៉ម ប៊ុនហេង | រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| | លោកជំទាវ យក់ សម្បត្តិ | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| | លោកជំទាវ វេជ្ជបណ្ឌិត ឱ វណ្ណឌីន | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| | ឯកឧត្តម សុខ សំអាង | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុក្រសួងសុខាភិបាល |
| | ឯកឧត្តម វេជ្ជបណ្ឌិត ស៊ុង វិនតាក់ | ទីប្រឹក្សានិងអគ្គនាយករងការិយាល័យសហប្រតិបត្តការអន្តរជាតិក្រសួងសុខាភិបាល |

សមាសភាពពីក្រុមហ៊ុនអ៊ីអនគ្រុប:

| **ឈ្មោះក្រុមហ៊ុន** | **នាម·គោត្តនាម** | **មុខតំណែង** |
|---|---|---|
| ក្រុមហ៊ុនអ៊ីអនម៉ល (ខេមបូឌា) ខូអិលធីឌី | Mr. Tsuboya Masayuki | អគ្គនាយកក្រុមហ៊ុន |
| ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី | Mr. Ando Taketo | អគ្គនាយកក្រុមហ៊ុន |
| ក្រុមហ៊ុនអ៊ីអន ឌីឡៃថ៍ (វៀតណាម) ខមភេនី លីមីធីត | Mr. Nakanishi Manabu | អ្នកគ្រប់គ្រងទូទៅនៃសាខា |
| ក្រុមហ៊ុនអ៊ីអន (ខេមបូឌា) ខូអិលធីឌី | Mr. Seko Tsugutoshi | អគ្គនាយកក្រុមហ៊ុន |





